ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣✣៨

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ ៦១២ អក

ចុះថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០២១

សាលក្រមព្រហ្មទណ្ឌលេខ: ១៥ "ផ" ក្រ

ចុះថ្ងៃអង្គារ ១១កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ត្រូវនឹងថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០២១

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ០៩ និង ០០ នាទីព្រឹក ដោយមានសមាសភាពចូលរួមដូចខាងក្រោម ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

### មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

លោក [redacted]និងមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]សារឿន ហៅ វុធ

-ដើម្បីធ្វើការជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៦១២ អក ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២១ ដែលមានជនជាប់ចោទដូចខាងក្រោម ៖

១-ឈ្មោះ [redacted]សារឿន ហៅ វុធ ភេទប្រុស អាយុ ១៥ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ ភាព "រ" ម្ដាយឈ្មោះ [redacted] សារ៉េត "រ" អនីតិជន។ (ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៣១៤/២១ ដកបយខ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល ។

ត្រូវចោទពីបទ៖ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិព្រែកតាទៀង ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារ៉េត ភេទស្រី អាយុ ៣៥ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ ភូមិព្រែកតាទៀង ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្ដាល ។

-**បានឃើញ** របាយការណ៍សរុបលេខ ៤៧ របក ចុះថ្ងៃទី ១៨ ខែមេសា ឆ្នាំ ២០២១ របស់អធិការនគរបាលស្រុកកោះធំ ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៖ ៣៨៣ ដកសស ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ៖ ១០៤៦ ដកសព ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ៖ ១១៣៧ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល ។

-**បានឃើញ** ដីកាសម្រេចរក្សាទុកជនត្រូវចោទឱ្យនៅក្នុងឃុំបណ្ដោះអាសន្នលេខ ៩៦៩/២១ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល ។

## អង្គហេតុនៃរឿងមានដូចតទៅ:

កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ១១ និ ៣០ នាទី ស្ថិតនៅក្នុងភូមិព្រែកតាទៀង ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្ដាល មានជនរងគ្រោះឈ្មោះ [redacted] សារ៉េត ត្រូវជាម្ដាយរបស់ជនសង្ស័យឈ្មោះ [redacted] សារឿន ហៅ វុធ បានទទួលព័ត៌មានថាជនសង្ស័យជាកូនរបស់ខ្លួនបានទៅជក់ថ្នាំញៀននៅផ្ទះរបស់ឈ្មោះ ផល្លា ពេលនោះជនរងគ្រោះបានស្ដីបន្ទោសឱ្យជនសង្ស័យ ស្រាប់តែជនសង្ស័យបានវាយជនរងគ្រោះចំនួន ០១ដៃ ចំថ្ងាសខាងឆ្វេងបណ្ដាលឱ្យហើមប៉ោង ស្របពេលនោះជីតារបស់ជនសង្ស័យឈ្មោះ [redacted] យ៉ែម បានចូលមកជួយឃាត់ ក៏ត្រូវជនសង្ស័យចាប់ទាញកៅអីជ័រតូចវាយ ០១ កៅអី ចំថ្ងាសខាងឆ្វេង ក្រោមភ្នែក និងក្រោមចុងច្រមុះបណ្ដាលឱ្យបែកហូរឈាមតែម្ដង។ ក្រោមមកជនរងគ្រោះបានដាក់ពាក្យបណ្ដឹងឈានដល់ការឃាត់ខ្លួនជនសង្ស័យខាងលើបញ្ជូនមកតុលាការដើម្បីជួយចាត់ការតាមនីតិវិធីច្បាប់។

## នាពេលសវនាការ

១-ជនជាប់ចោទឈ្មោះ [redacted]សារឿន ហៅ វុធ បានឆ្លើយថា: នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ម៉ោង ១២ ថ្ងៃត្រង់ ខ្ញុំពិតជាបានវៃម្ដាយខ្ញុំឈ្មោះ [redacted] សារ៉េត ចំនួន ១ដៃចំថ្ងាស បណ្ដាលឱ្យពក ដោយមូលហេតុដំបូងម្ដាយខ្ញុំថាឱ្យខ្ញុំកុំឱ្យដើរផ្ទះគេ ហើយខ្ញុំខឹងក៏ចាក់ឆ្នាំងស្ងោរនំចោល ក៏ម្ដាយខ្ញុំខឹងយកដង្កៀបទំវៃខ្ញុំ ពេលនោះខ្ញុំខឹងក៏ដាល់ត្រូវចំថ្ងាសមុខម្ដាយដែលបណ្ដាលឱ្យពក គាត់ក៏ប្ដឹងសមត្ថកិច្ចឱ្យចាប់ខ្ញុំតែម្ដង។ ខ្ញុំធ្លាប់ប្រើគ្រឿងញៀនរយះពេល ០១ឆ្នាំមកហើយ គឺសព្វថ្ងៃខ្ញុំជក់ថ្នាំញៀនមួយខែពីរដង គេហៅជក់តែម្ដង។ ពេលឃាត់ខ្លួនពុំដកហូតអ្វីលើខ្លួនខ្ញុំទេ។ ខ្ញុំសុំសំណូមពរឱ្យតុលាការបន្ធូរទោសដល់រូបខ្ញុំផង។

២-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារ៉េត បានឆ្លើយថា: នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ម៉ោង ១១ ថ្ងៃ កូនខ្ញុំឈ្មោះ[redacted]សារឿន ត្រឡប់ពីទិញបារីជក់ ក៏នាងខ្ញុំសួរកូនថា មានរឿងអ្វីបានជាគេមកសួរដល់ផ្ទះ ក៏



Scanned with CamScanner

វាឆ្លើយថាកុំចេះអី ក៏ខ្ញុំរើវា ក៏វាគេដៃជាមួយនាងខ្ញុំរើនាងខ្ញុំមួយដៃចំមុខ ក៏ឪពុកខ្ញុំជួយឃាត់ ក៏កូនលើកកៅអីមកប៉ះឪពុកនាងខ្ញុំចំថ្ងាសចេញឈាមបន្តិច ក៏ខ្ញុំឃើញអញ្ចឹងក៏ហៅសមត្ថកិច្ចឱ្យយកវាទៅប៉ុស្តិ៍ណែនាំកូន។ ពេលនេះនាងខ្ញុំសុំដកពាក្យបណ្តឹងចាប់ពីពេលនេះតទៅ និងសុំឱ្យតុលាការជួយដោះលែងកូនប្រុសនាងខ្ញុំចុះ។

៣-ជនរងគ្រោះឈ្មោះ [redacted] យ៉ែម បានឆ្លើយថាៈ មុនពេលកើតហេតុរូបខ្ញុំបាទគឺកំពុងដេកអង្រឹងនៅខាងក្រោមផ្ទះ ក្រោយមកកូនរបស់ខ្ញុំបាទឈ្មោះ [redacted] សុភាព ភេទស្រី បានហៅខ្ញុំបាទឱ្យមកហូបបាយបានមួយម៉ាត់ ស្រាប់តែកូនរបស់ខ្ញុំបាទឈ្មោះ [redacted] សារ៉េត ភេទស្រី អាយុ ៣៥ឆ្នាំ ត្រូវជាម្តាយរបស់ឈ្មោះ [redacted] សារឿន ហៅ វុធ ជនសង្ស័យ បានស្តីបន្ទោសអប់រំណែនាំកូនរបស់ខ្លួនឈ្មោះ [redacted] សារឿន ហៅ វុធ ឱ្យឈប់ទៅដើរលេងនៅផ្ទះគេទៀតស្រាប់តែឈ្មោះ [redacted] សារឿន ហៅ វុធ ជាជនសង្ស័យ បានឆ្លើយតបទៅម្តាយរបស់ខ្លួនថា "ពួកឯងកុំមកប្រដៅអញ" ភ្លាមនោះរូបខ្ញុំបាទក៏បានឃើញទាំងពីរនាក់ម្តាយនិងកូនបានប្រតាយប្រតប់គ្នា ឃើញដូចនោះរូបខ្ញុំបាទក៏ចូលទៅឃាត់ កូនស្រីរបស់ខ្ញុំបាទ និងចៅប្រុសកុំឱ្យឈ្លោះគ្នា ពេលនោះស្រាប់ឈ្មោះ [redacted] សារឿន ជាជនសង្ស័យបានចាប់ទាញយកកូនកៅអីជ័រវាយមកលើរូបខ្ញុំបាទត្រូវចំថ្ងាសខាងឆ្វេង ក្រោមភ្នែកខាងឆ្វេង និងចុងច្រមុះខាងឆ្វេងបណ្តាលឱ្យរងរបួសហូរឈាមតែម្តង(វាយតែមួយកៅអីប៉ុណ្ណោះ) ក្រោយពេលកើតហេតុកូនស្រីរបស់ខ្ញុំបាទឈ្មោះ [redacted] សុភាព ភេទស្រី បានតេប្តឹងមកប៉ុស្តិ៍នគរបាលតែម្តង។

៤-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំៈ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់ជនរងគ្រោះ ព្រមទាំងវត្ថុតាងនានាក្នុងសំណុំរឿង ឃើញថា មានភាពស៊ីចង្វាក់គ្នាទៅនិងអង្គហេតុ ថាពិតជាបានប្រព្រឹត្តអំពើ ហិង្សាដោយចេតនា ពិតប្រាកដមែន ដែលអំពើនេះបានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ដូច្នេះតំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរដដែល និងស្នើសុំឱ្យតុលាការផ្តន្ទាទោសទៅតាមផ្លូវច្បាប់ ។

៥-មេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថាៈ កូនក្តីខ្ញុំបាទឈ្មោះ [redacted] សារឿន ហៅ វុធ បានឆ្លើយសារភាពនិងទទួលស្គាល់នូវអំពើរបស់ខ្លួន នៅគ្រប់ដំណាក់កាលទាំងមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់ការអយ្យការ រួមទាំងដំណាក់កាលចៅក្រមស៊ើបសួរ លើសពីនេះទៀតកូនក្តីរបស់ខ្ញុំបាទ ជាអនីតិជន មិនបានគិតវែងឆ្ងាយ និងមិនបានរៀនជ្រៅជ្រះ ជាហេតុនាំឱ្យប្រព្រឹត្តបទល្មើសដូចដែលបានចោទប្រកាន់ខាងលើ។ យើងខ្ញុំស្នើសុំលោកចៅក្រម មេត្តាសម្រាលទោសដល់កូនក្តីខ្ញុំបាទឈ្មោះ [redacted] សារឿន ហៅ វុធ ដោយក្តីអនុគ្រោះ។

៦-សម្តីចុងក្រោយរបស់ជនជាប់ចោទៈ ស្នើសុំឱ្យតុលាការបន្ធូរបន្ថយទោស ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាងនានា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

## សំអេចហេតុ

១-កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ១១ និ ៣០ នាទី ស្ថិតនៅក្នុងភូមិព្រៃកតាទៀង ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្ដាល មានជនរងគ្រោះឈ្មោះ [redacted] សារ៉េត ត្រូវជាម្ដាយរបស់ជនសង្ស័យឈ្មោះ [redacted] សារឿន ហៅ វុធ បានទទួលព័ត៌មានថាជនសង្ស័យជាកូនរបស់ខ្លួនបានទៅជក់ថ្នាំញៀននៅផ្ទះរបស់ឈ្មោះ ផល្លា ពេលនោះជនរងគ្រោះបានស្ដីបន្ទោសឱ្យជនសង្ស័យ ស្រាប់តែជនសង្ស័យបានវាយជនរងគ្រោះចំនួន ០១ដៃ ចំថ្ពាសខាងឆ្វេងបណ្ដាលឱ្យហើមប៉ោង ស្របពេលនោះជីតារបស់ជនសង្ស័យឈ្មោះ [redacted] យ៉ែម បានចូលមកជួយឃាត់ ក៏ត្រូវជនសង្ស័យចាប់ទាញកៅអីជ័រតូចវាយ ០១ កៅអី ចំថ្ពាសខាងឆ្វេង ក្រោមភ្នែក និងក្រោមចុងច្រមុះបណ្ដាលឱ្យបែកហូរឈាមតែម្ដង។ ក្រោយមកជនរងគ្រោះបានដាក់ពាក្យបណ្ដឹងឈានដល់ការឃាត់ខ្លួនជនសង្ស័យខាងលើបញ្ជូនមកតុលាការដើម្បីជួយចាត់ការតាមនីតិវិធីច្បាប់។

២-ជនជាប់ចោទឈ្មោះ [redacted] សារឿន ហៅ វុធ បានឆ្លើយថា: នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ម៉ោង ១២ ថ្ងៃត្រង់ ខ្ញុំពិតជាបានវៃម្ដាយខ្ញុំឈ្មោះ [redacted] សារ៉េត ចំនួន ១ដៃចំថ្ពាស បណ្ដាលឱ្យពក ដោយមូលហេតុដំបូងម្ដាយខ្ញុំថាឱ្យខ្ញុំកុំឱ្យដើរផ្ទះគេ ហើយខ្ញុំខឹងក៏ចាក់ឆ្នាំងស្ងោរនំចោល ក៏ម្ដាយខ្ញុំខឹងយកដង្កៀបនំវៃខ្ញុំ ពេលនោះខ្ញុំខឹងក៏ដាល់ត្រូវចំថ្ពាសមុខម្ដាយដែលបណ្ដាលឱ្យពក គាត់ក៏ប្ដឹងសមត្ថកិច្ចឱ្យចាប់ខ្ញុំតែម្ដង។ ខ្ញុំធ្លាប់ប្រើគ្រឿងញៀនរយៈពេល ០១ឆ្នាំមកហើយ គឺសព្វថ្ងៃខ្ញុំជក់ថ្នាំញៀនមួយខែពីរដង គេហៅជក់តែម្ដង។ ពេលឃាត់ខ្លួនពុំដកហូតអ្វីលើខ្លួនខ្ញុំទេ។ ខ្ញុំសំសំណូមពរឱ្យតុលាការបន្ថយទោសដល់រូបខ្ញុំផង។

៣-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារ៉េត បានឆ្លើយថា: នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ម៉ោង ១១ ថ្ងៃ កូនខ្ញុំឈ្មោះ [redacted] សារឿន ត្រឡប់ពីទិញបារីជក់ ក៏នាងខ្ញុំសួរកូនថា មានរឿងអ្វីបានជាគេមកសួរដល់ផ្ទះ ក៏វាឆ្លើយថាកុំចេះអី ក៏ខ្ញុំវៃវា ក៏វាតដៃជាមួយនាងខ្ញុំវៃនាងខ្ញុំមួយដៃចំមុខ ក៏ឪពុកខ្ញុំជួយឃាត់ ក៏កូនលើកកៅអីមកប៉ះឪពុកនាងខ្ញុំចំថ្ពាសចេញឈាមបន្តិច ក៏ខ្ញុំឃើញអញ្ចឹងក៏ហៅសមត្ថកិច្ចឱ្យយកវាទៅប៉ុស្តិ៍ណែនាំកូន។ ពេលនេះនាងខ្ញុំសុំដកពាក្យបណ្ដឹងចាប់ពីពេលនេះតទៅ និងសុំឱ្យតុលាការជួយដោះលែងកូនប្រុសនាងខ្ញុំចុះ។

៤-ជនរងគ្រោះឈ្មោះ [redacted] យ៉ែម បានឆ្លើយថា: មុនពេលកើតហេតុរូបខ្ញុំបាទគឺកំពុងដេកអង្រឹងនៅខាងក្រោមផ្ទះ ក្រោយមកកូនរបស់ខ្ញុំបាទឈ្មោះ [redacted] សុភាព ភេទស្រី បានហៅខ្ញុំបាទឱ្យមកហូបបាយបានមួយម៉ាត់ ស្រាប់តែកូនរបស់ខ្ញុំបាទឈ្មោះ [redacted] សារ៉េត ភេទស្រី អាយុ ៣៥ឆ្នាំ ត្រូវជាម្ដាយរបស់ឈ្មោះ [redacted] សារឿន ហៅ វុធ ជនសង្ស័យ បានស្ដីបន្ទោសអប់រំណែនាំកូនរបស់ខ្លួនឈ្មោះ ស៊ិន សារឿន ហៅ វុធ ឱ្យឈប់ទៅដើរលេងនៅផ្ទះគេទៀតស្រាប់តែឈ្មោះ [redacted] សារឿន ហៅ វុធ ជាជនសង្ស័យ បានឆ្លើយតបទៅម្ដាយរបស់ខ្លួនថា “ពួកឯងកុំមកប្រដៅអញ” ភ្លាមនោះរូបខ្ញុំបាទក៏បានឃើញទាំងពីរនាក់ម្ដាយនិងកូនបានប្រតាយប្រតប់គ្នាឃើញដូចនោះរូបខ្ញុំបាទក៏ចូលទៅឃាត់ កូនស្រីរបស់ខ្ញុំបាទ និងចៅប្រុសកុំឱ្យឈ្លោះគ្នា ពេលនោះស្រាប់ឈ្មោះ [redacted] សារឿន ជាជនសង្ស័យបានចាប់ទាញយកកូនកៅអីជ័រវាយមកលើរូបខ្ញុំបាទត្រូវចំថ្ពាសខាងឆ្វេង ក្រោមភ្នែកខាងឆ្វេង និងចុងច្រមុះខាងឆ្វេងបណ្ដាលឱ្យរងរបួសហូរឈាមតែម្ដង(វាយតែមួយកៅអីប៉ុណ្ណោះ) ក្រោយពេលកើតហេតុកូនស្រីរបស់ខ្ញុំបាទឈ្មោះ [redacted] សុភាព ភេទស្រី បានតេប្ដឹងមកប៉ុស្តិ៍នគរបាលតែម្ដង។



Scanned with CamScanner

៥.តាមចម្លើយសារភាពរបស់ជនជាប់ចោទ នៅគ្រប់ដំណាក់កាលទាំងនៅមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ ក៏ដូចជាដំណាក់កាលចៅក្រមស៊ើបសួរ មានភាពស៊ីចង្វាក់គ្នាទៅនឹងអង្គហេតុ ក៏ដូចជាភស្តុតាងនានា នៅក្នុងសំណុំរឿងដោយបញ្ជាក់អោយឃើញថាជនជាប់ចោទ ដែលអាចបញ្ជាក់បានថានៅថ្ងៃកើតហេតុជនជាប់ចោទឈ្មោះ [redacted] សារឿន ពិតជាបានប្រព្រឹត្តអំពើដូចបានចោទប្រកាន់ពិតប្រាកដមែន ដែលអំពើប្រព្រឹត្តរបស់ជនជាប់ចោទរូបនេះច្បាប់ចាត់ទុកជាបទល្មើស **ហិង្សាដោយចេតនា** ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២១៧** នៃក្រមព្រហ្មទណ្ឌ។

៦-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាន មានលក្ខណៈសមហេតុផលខ្លះ អាចឱ្យតុលាការទទួលយកមកពិចារណាបាន ។

៧.អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឱ្យប៉ះពាល់ដល់រូបរាងកាយរបស់អ្នកដទៃ ដែលច្បាប់ត្រូវការពារ និងតម្រូវឱ្យធ្វើការផ្តន្ទាទោស ។

៨.ជនជាប់ចោទរូបនេះ ជាសមត្ថជនមានស្មារតីល្អគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនូវរាល់អំពើដែលខ្លួនបានប្រព្រឹត្តចំពោះមុខច្បាប់ ។

៩-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **សារឿន ហៅ វុធ** ភេទប្រុស អាយុ ១៥ ឆ្នាំ សញ្ជាតិខ្មែរ ពីបទ៖ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិព្រែកតាទៀង ឃុំជ្រាយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា **២១៧** នៃក្រមព្រហ្មទណ្ឌ។

១០-ជនជាប់ចោទឈ្មោះ [redacted] **សារឿន ហៅ វុធ** ជាអនីតិជន អាយុទើបតែ ១៥ឆ្នាំ ស្ថិតក្នុងវ័យក្តៅគគ្លើន ខ្វះការពិចារណាឱ្យបានជ្រៅជ្រះ ទើបបណ្តាលឱ្យប្រព្រឹត្តបទល្មើស ដូច្នេះហើយជនជាប់ចោទរូបនេះ ទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង ហើយត្រូវបន្តការសិក្សាទៅមុខទៀត ដើម្បីអាចកែខ្លួនជាពលរដ្ឋល្អឡើងវិញ ហេតុដូច្នេះគប្បីតុលាការពិចារណាសម្រេចអំពីស្ថានសម្រាលទោស ដល់ជនជាប់ចោទ ដើម្បីទុកឱកាសឱ្យពួកគេកែប្រែខ្លួនធ្វើជាពលរដ្ឋល្អជាថ្មី បន្តការសិក្សាស្វែងរកអនាគតល្អឡើងវិញ ដោយផ្តល់នូវស្ថានសម្រាលទោសតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

១១-វត្ថុតាងចាប់យកមាន៖ កៅអីជ័រតូច ០១ ពណ៌ក្រហមឈាមជ្រូក(មិនប្រក្រតី)។

១២-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សារ៉េត** បានដកពាក្យបណ្តឹងនៅក្នុងចម្លើយដែលបានឆ្លើយនៅដំណាក់ការចៅក្រមស៊ើបសួរចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១។ គប្បីតុលាការមិនយកចំណុចនេះមកពិចារណា និងសម្រេចនោះទេ ។

## ហេតុដូច្នេះសម្រេច

**១- ផ្តន្ទាទោស** ៖ ជនជាប់ចោទឈ្មោះ [redacted] **សារឿន** ភេទប្រុស អាយុ ១៥ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ៦ (ប្រាំមួយ) ខែ ។

ពីបទ៖ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិព្រែកតាទៀង ឃុំជ្រាយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា **២១៧** និងមាត្រា **១៦០** នៃក្រមព្រហ្មទណ្ឌ។

**២**-វត្ថុតាងចាប់យកដែលត្រូវរឹបអូសមាន៖កៅអីជ័រតូច ០១ ពណ៌ក្រហមឈាមជ្រូក(មិនប្រក្រតី)។



Scanned with CamScanner

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សារឿន ហៅ វុធ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ប៉ែម សារ៉េត និងប្រកាសជាសាធារណៈនៅថ្ងៃទី២០ ខែកក្កដាឆ្នាំ ២០២១ ។

ទុកសិទ្ធិប្តឹងទាស់ ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា |

[redacted]

---

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមសាលក្រមដើម

ថ្ងៃអង្គារ ១១កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

កណ្តាល, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០២១

**ក្រឡាបញ្ជីសវនាការ**

[redacted]

ថ្ងៃ 20-07-2021

[redacted]

22.07.2021

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

កណ្តាល. ថ្ងៃទី 26 ខែ 11 ឆ្នាំ 2021

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner